**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ១៩ អនក្រ.បក

# អនុក្រឹត្យ

# ស្តីពី

# ការកែសម្រួលអនុក្រឹត្យស្តីពីការរៀបចំនិង ការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៦ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់
- បានឃើញអនុក្រឹត្យលេខ៣៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ១៣៥ អនក្រ.បក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់



https://www.moj.gov.kh/kh/law-regular

- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សម្រេច**

**មាត្រាមួយ .-**

មាត្រា២នៃអនុក្រឹត្យលេខ១៣៥ អនក្រ.បក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់ ត្រូវបានធ្វើការកែសម្រួលដូចតទៅ៖

**មាត្រា២ .- ថ្មី**

គ.ជ.ក.ប. មានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| - រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម | ប្រធាន |
| - តំណាងក្រសួងពាណិជ្ជកម្ម ១រូប | អនុប្រធានអចិន្ត្រៃយ៍ |
| - តំណាងទីស្តីការគណៈរដ្ឋមន្ត្រី ១រូប | អនុប្រធាន |
| - តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ១រូប | អនុប្រធាន |
| - តំណាងក្រសួងមហាផ្ទៃ ១រូប | អនុប្រធាន |
| - តំណាងក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ១រូប | អនុប្រធាន |
| - តំណាងក្រសួងយុត្តិធម៌ ១រូប | អនុប្រធាន |
| - តំណាងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ១រូប | សមាជិក |
| - តំណាងក្រសួងសុខាភិបាល ១រូប | សមាជិក |
| - តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ១រូប | សមាជិក |
| - តំណាងក្រសួងព័ត៌មាន ១រូប | សមាជិក |
| - តំណាងធនាគារជាតិនៃកម្ពុជា ១រូប | សមាជិក |
| - តំណាងក្រុមប្រឹក្សាអ្នកច្បាប់នៃទីស្តីការគណៈរដ្ឋមន្ត្រី ១រូប | សមាជិក |
| - អគ្គនាយកនៃអគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ | សមាជិកនិងជាលេខាធិការ។ |

សមាសភាពនៃ គ.ជ.ក.ប. មានចំនួនមិនលើសពី១៥(ដប់ប្រាំ)រូប។

សមាសភាពជាក់ស្តែងនៃ គ.ជ.ក.ប. ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

**មាត្រាពីរ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។



https://www.moj.gov.kh/kh/law-regular

**មាត្រាបី ..**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ព្រហស្បតិ៍ ៧ រោច ខែ បុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១ ខែ កុម្ភៈ ឆ្នាំ ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្ដីគោរពជម្រាបជូន

សម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម និម្មល**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រាបី
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ



https://www.moj.gov.kh/kh/law-regular